# កុំភ្លេចជាតិខ្លួន

ជនជាតិខ្មែរកើតនៅលើដីខ្មែរ យើងត្រូវខំថែជាតិឱ្យបានរុងរឿង
កេរ្តិ៍ឈ្មោះជាតិយើងបានថ្កុំថ្កើង លុះត្រាតែយើងចេះថែរក្សា ។
ទោះបីខ្មែររស់នៅប្រទេសណា ចូរកុំភ្លេចថាខ្លួនកើតមកជាខ្មែរ
កុំឱ្យបរទេសគេមកបង្វែរ ឱ្យខ្មែរនិងខ្មែរបែកសាមគ្គីគ្នា
ថ្វីបើគេហ៊ានចំណាយ ប្រាក់កើតចាយហូរហៀរយ៉ាងណា
ចូរកុំភ្លេចកេរ្តិ៍ឈ្មោះខេមរា រុងរឿងថ្លៃថ្លាតាំងពីបុរាណ
ព្រលឹងជាតិនូវគង់វង្សបានយូរ លុះតែយើងស៊ូរួបរួមគ្នាគ្រប់ប្រាណ
កសាងជាតិដោយក្តីក្លាហាន លុះជាតិយើងបានស្គាល់ក្តីរុងរឿង ។៕

"ច្រៀងពីរដង"

ចម្លងជូនដោយខ្ញុំបាទ **គុណ សារ៉ា**

វាយចម្លងដាក់គេហទំព័រវត្តកុំភ្លេចជាតិខ្លួនដោយខ្ញុំបាទ អ៊ិន លី ថ្ងៃទី៩ខែកុម្ភៈឆ្នាំ២០១២